ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង
សំណុំរឿងព្រហ្មទណ្ឌលេខ: ១០៧
ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៧
សាលក្រមលេខ: ១១០ "ខ"
ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ២,៣០នាទីរសៀល ដោយមានសមាសភាពដូចតទៅ៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រុមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកោះកុង

-ដើម្បីជំនុំជម្រះលើ៖ សំណុំរឿងព្រហ្មទណ្ឌលេខ: ១០៧ ចុះថ្ងៃទី ១១-៥-២០១៧ អញ្ញតជន ត្រូវចោទពីបទ: កាប់គាស់ រុករានដីព្រៃ-ឆ្ការ ដុត និងឈូស ឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចនិយាមការលេខ: ៣២៨៨៣៦-១២៩២២៧៩៦១ ស្ថិតនៅភូមិត្រពាំងឈើក្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី ១៦.០៣.២០១៧ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦២ ចំណុច ១ និងមាត្រា ៩៦ ចំណុច ៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ ១១៣ អ.យ/១៧ ចុះថ្ងៃទី ២៤-០៨-២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

-បានឃើញ: ដីកាបញ្ជូនរឿងទៅជំនុំជម្រះឲ្យសម្រេចរបស់លេខ ១៧០៦ ត.៣/១៧ ចុះថ្ងៃទី ២៤-០៨-២០១៧ របស់ចៅក្រមសាលាដំបូងខេត្តកោះកុង ។

-បានឃើញ: ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១១៥ ចុះថ្ងៃទី ៣០-០៨-២០១៧ របស់លោកប្រធានសាលាដំបូងខេត្តកោះកុង ។

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧ ត្រង់ចំណុចនិយាមការលេខ: ៣២៨៨៣៦-១២៩២២៧៩៦១ ស្ថិតនៅតំបន់កោះខ្សាច់ ក្នុងភូមិត្រពាំងឈើក្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង មានសកម្មភាព កាប់គាស់រុករានដីព្រៃ ឆ្ការដុត ដើម្បីយកធ្វើជាកម្មសិទ្ធិ មានទំហំ ០,០១០ហិកតា ដោយគ្មានការអនុញ្ញាតកើតឡើង ដែលប្រព្រឹត្តដោយជនមិនស្គាល់ មុខ។

នាពេលសវនាការ

-សាក្សីឈ្មោះ [redacted] ភ័ន បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧ [illegible] ម៉ោង ១០,៣០នាទី ក្រុមមន្ត្រីរដ្ឋបាលការពារអភិរក្សធម្មជាតិ សហការជាមួយ [illegible]

Scanned by CamScanner

ហត្ថលេខា សីផ្ទៃប្រទេស និងភូមិភាគ បានចុះប្រត្តិបត្តការត្រង់ចំណុចនិយាមការលេខ ៣២៨៨៣៦-១២៩២២៧៦ ស្ថិតនៅក្នុងតំបន់កោះខ្សាច់ ក្នុងភូមិសាស្ត្រភូមិក្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង បានជួបប្រទះឃើញការកាប់គាស់ រុករានដីព្រៃ ដុត ឆ្ការ ដើម្បីធ្វើជាកម្មសិទ្ធិ ដែលមានទំហំ ០,០១០ ហិកតា ដោយគ្មានលិខិតអនុញ្ញាត ដែលប្រព្រឹត្តឡើងដោយជនមិនស្គាល់មុខ បន្ទាប់មកក្រុមសមត្ថកិច្ចយើងខ្ញុំបានធ្វើកំណត់ហេតុបណ្ដោះអាសន្ន ដើម្បីកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមផ្លូវច្បាប់ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានទោសថា: មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើ អញ្ញាតជន ពីបទៈប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចនិយាមការលេខ: ៣២៨៨៣៦-១២៩២២៧៩៦១ ស្ថិតនៅភូមិក្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី ១៦.០៣.២០១៧ បទល្មើសដែលចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៦២ ចំណុច ១ និងមាត្រា៥៦ ចំណុច ៤ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ។ តាងនាមតំណាងអយ្យការ សូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល និងស្នើសុំឲ្យតុលាការសម្រេចទៅតាមច្បាប់។

- ក្រោយពីបានស្ដាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- ក្រោយពីបានពិនិត្យភស្តុតាង

<u>ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ</u>

<u>យល់ឃើញថា:</u>

-កាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧ នៅភូមិក្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង មានអំពើល្មើស កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ចំពោះអំពើល្មើសនេះ ត្រូវបានច្បាប់ចែងឲ្យផ្ដន្ទាទោសត្រង់មាត្រា ៦២ ចំណុច ១ និងមាត្រា៥៦ ចំណុច០៤ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។

-តុលាការមានអង្កេត និងស៊ើបសួរ បង្ហាញថា ដីដែលជនជាប់ចោទ លួច កាប់គាស់ និងឈូសឆាយគឺជាដីរបស់រដ្ឋ ហើយអំពើរបស់ជនជាប់ចោទ គឺជាអំពើបំពានច្បាប់ ហេតុដូច្នេះគប្បីរឹបអូសដីនេះជាសម្បត្តិរដ្ឋតាមនីតិវិធី ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ សុំឲ្យតុលាការសម្រេចរឹបអូសដីដែលជនជាប់ចោទលួចកាប់ឆ្ការនោះ ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ គប្បីតុលាការពិចារណា។

<u>ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង</u>

<u>វិនិច្ឆ័យសេចក្ដី</u>

១/-រឹបអូសដីព្រៃដែលមានទំហំ ០,០១០ "សូន្យក្បៀសសូន្យមួយសូន្យ"ហិកតា នៅចំណុចចំណុចនិយាមការលេខ: <u>៣២៨៨៣៦-១២៩២២៧៩៦១</u> ស្ថិតនៅភូមិក្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង ទុកជាសម្បត្តិរដ្ឋ ។

២/-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧ បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ហត្ថលេខានិងត្រា [redacted]

ហត្ថលេខានិងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កោះកុង, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧

ក្រឡាបញ្ជីសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

[redacted]



Scanned by CamScanner